**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍**
**និងគ្រឿងញៀន**
លេខៈ ០០៤ កប/គបអគញ

**<u>សូមគោរពជូន</u>**
**ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**កម្មវត្ថុ:** របាយការណ៍បូកសរុបលទ្ធផលការងារស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងគ្រឿងញៀនប្រចាំត្រីមាសទី១ និងទិសដៅអនុវត្តត្រីមាសទី២ ឆ្នាំ២០១៨។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សូមជម្រាបជូន **ឯកឧត្តមប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាបដូចខាងក្រោម:

**ក- <u>លទ្ធផលការងារដែលសម្រេចបាន</u>**

**I-<u>ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង</u>**

-សកម្មភាពអប់រំ ផ្សព្វផ្សាយដល់សិស្ស និស្សិតកម្មករនិយោជិតស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣នៅកម្ពុជារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សរុបចំនួន ៧.៥៦១ នាក់ ( ស្ត្រី ៤.៥២៨ នាក់ )។

**II-<u>ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មការសម្របសម្រួលត្រីភាគី</u>**<u>( TCC )</u>

-កិច្ចប្រជុំលើកទី ២សម្រាប់ ឆ្នាំ២០១៧នៃគណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ ក្រោមអធិបតីភាព ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀនសរុបសមាជិកចូលរួម២៩នាក់( ស្រី១២នាក់)នៅអគារទីស្តីការក្រសួង។

**III-<u>ការងារអប់រំអេដស៍ដល់ពលករត្រៀមទៅធ្វើការនៅប្រទេសកូរ៉េ(៥មេរៀន)</u>**

-បានផ្តល់ចំណេះដឹងពីស្ថានភាព មូលដ្ឋានគ្រឹះមេរោគអេដស៍ និងជំងឺអេដស៍ ជំងឺកាមរោគ គ្រឿងញៀន ការប្រើស្រោមអនាម័យដល់ពលករត្រៀមចាកចេញទៅធ្វើការនៅប្រទេសកូរ៉េរៀបចំនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) ចំនួន ០៥វគ្គ សរុប ៧៤៧ នាក់ ក្នុងនោះស្ត្រីចំនួន ៣២១នាក់ និងបុរស ៤២៦៨នាក់ (ឧស្សាហកម្ម ៥៤៦ នាក់ កសិកម្ម ២០១នាក់ និងសំណង់

០នាក់) (ជូនភ្ជាប់នូវតារាងឧបសម្ព័ន្ធ)។

IV-**ការចូលរួមប្រជុំ និងសិក្ខាសាលាជាមួយស្ថាប័នពាក់ព័ន្ធ**

-ចូលរួមសន្និបាតគ្រឿងញៀនចូលរួមដោយ ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុខ** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន ឯកឧត្តម **ឡេង សៃ** អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍និងគ្រឿងញៀន និងលោកជំទាវ **ម៉ៅ ធីតា** អគ្គនាយករងនៃអគ្គនាយកដ្ឋានការងារ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៨ នៅក្រសួងមហាផ្ទៃ។

**ខ-ទិសដៅអនុវត្តបន្ត**

-បន្តផ្សព្វផ្សាយ និងណែនាំការចុះជំរុញការអនុវត្តប្រកាសលេខ០៨៦ ក.ក.ប.វ/ប្រ.ក ស្តីពីការបង្កើតគណៈ កម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាននៅតាមរាជធានី ខេត្ត។

-បន្តអប់រំពីមេរោគអេដស៍និងជំងឺអេដស៍ និងគ្រឿងញៀនដល់ពលករទៅធ្វើការនៅប្រទេសកូរ៉េ។

-បន្តអប់រំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន។

-បន្តកិច្ចសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ( NAA ) អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អង្គការ SIPAR UNFPA និងអង្គការ APHEDA ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំបាទ។

ថ្ងៃសុក្រ ១៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨

**ប្រធាន**

**វេជ្ជ. ហ៊ុយ ហានសុខ**

12 - 4 - 18

ចម្លងជូន:
-នាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
-ឯកសារ-កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធការអប់រំមេរោគអេដស៍/ជំងឺអេដស៍

| ល.រ | បរិយាយ | ភេទ | ប្រចាំ ត្រីមាសទី១ ឆ្នាំ២០១៨ | ប្រចាំ ត្រីមាសទី១ ឆ្នាំ២០១៧ | ប្រៀបធៀប (%) |
|---|---|---|---|---|---|
| | | | ១ | ២ | ៣=( ១-២ )/២ |
| ១ | ការអប់រំមេរោគអេដស៍/ជំងឺអេដស៍ដល់ពលករត្រៀមទៅធ្វើការនៅប្រទេសកូរ៉េ | សរុប | ៧៤៧ | ៣៥៨ | ១០៨.៦៥ |
| | | ស្រី | ៣២១ | ៩០ | ២៥៦.៦៦ |

ប្រភព៖ លេខាធិការដ្ឋានអេដស៍ និងគ្រឿងញៀនប្រចាំត្រីមាសទី១ឆ្នាំ២០១៨